ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋានយោធសេវា
នាយកដ្ឋានព័ត៌មាន
លេខៈ០៣៧៦/…នទ ៧
២០១៦

# សេចក្តីប្រកាសព័ត៌មាន

នាយកដ្ឋានព័ត៌មាននៃអគ្គនាយកដ្ឋានយោធសេវាក្រសួងការពារជាតិ សូមជម្រាបជូនដំណឹងដល់សាធារណជនឲ្យបានជ្រាបថា តបតាមការអញ្ជើញរបស់ប្រធាន ADSOM ឡាវ ឯកឧត្តមនាយឧត្តមសេនីយ៍ **នាង ផាត** រដ្ឋលេខាធិការក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជានិងជាប្រធាន ADSOM កម្ពុជាព្រមទាំងប្រតិភូនឹងអញ្ជើញចូលរួមកិច្ចប្រជុំមន្រ្តីជាន់ខ្ពស់ការពារជាតិអាស៊ាន (Asean Defence Senior Officials Meeting ហៅកាត់ថា ADSOM) និង កិច្ចប្រជុំមន្រ្តីជាន់ខ្ពស់ការពារជាតិអាស៊ាន-បូក ( Asean Defence Senior Officials Meeting - Plus ហៅកាត់ថា ADSOM – Plus ) ដែលគ្រោងនឹងប្រព្រឹត្តិទៅពីថ្ងៃទី២២-២៥ ខែមេសា ឆ្នាំ២០១៦ នៅទីក្រុងវៀងច័ន្ទសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

ក្រសួងការពារជាតិនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលធ្វើជាប្រធាននៃកិច្ចប្រជុំរដ្ឋមន្រ្តីការពារជាតិ អាស៊ានលើកទី១០ ( The 10th Asean Defence Ministers Meeting "ADMM" ) នៅឆ្នាំ២០១៦នេះ នឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំ ADSOM និង ADSOM –Plusរយៈពេលបួនថ្ងៃពីថ្ងៃទី២២-២៥ខែមេសាឆ្នាំ២០១៦ដោយផ្តោតលើប្រធានបទសំខាន់ៗ មួយចំនួនដូចជាៈបណ្តាញមជ្ឈមណ្ឌលរក្សាសន្តិភាព (APCN) ,នីតិវិធីប្រតិបត្តិការតាមនិយាម ជំហាន១នៃ ADMMDCL, ការដាក់ដំណើរការជំហាន១នៃ DCL, ការពិភាក្សាពី ទីកន្លែង DCL , ការពិភាក្សាលើលក្ខខ័ណ្ឌប្រតិបត្តិនៃក្រុមត្រៀមខ្លួនជាស្រេចនៃយោធាអាស៊ាន (TOR នៃ AMRG), ការពិភាក្សាលើលក្ខខ័ណ្ឌប្រតិបត្តិនៃមជ្ឈមណ្ឌលវេជ្ជសាស្រ្តយោធាអាស៊ាន (TOR នៃ AMRC), ការពិចារណាលើឯកសារទស្សនទានស្តីពីការបង្កើតក្រុមការងារជំនាញស្តីពីសន្តិសុខអ៊ីនធើណែតក្របខ័ណ្ឌADMM - បូក (EWG on Cyber Security) ការពិភាក្សាលើសហ ប្រធានថ្មីនៃក្រុមការងារជំនាញក្របខ័ណ្ឌ ADMM -បូកជុំទី៣ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី 20 ខែមេសា ឆ្នាំ2016